# បរាជ័យទាំងសងខាង ?

ក្រុមលោក សម រង្ស៊ី និង កឹម សុខា មិនអាចចូលរួមគ្នាបាន ប្រហែលដោយសារ មានគោលដៅខុសគ្នា, ពោលថា ខាងក្រុមភាគច្រើន សម រង្ស៊ី, ការប្រញាប់ គឺធ្វើអោយ សម រង្ស៊ី មានលក្ខន្តិកៈ ជាអ្នកដឹកនាំស្របច្បាប់ឡើងវិញ នៅក្នុងគណបក្សសង្គ្រោះជាតិ ដើម្បី ឆ្លើយនឹងសេចក្តីត្រូវការទៅនឹងព្រឹត្តិការណ៍នយោបាយ នៅពេលដែល កឹម សុខា កំពុងជាប់ឃុំឃាំងនៅក្នុងភូមិគ្រឹះ។ រីឯ ក្រុមភាគតិច កឹម សុខា វិញ, គោលដៅគឺរក្សាសុវត្ថិភាពរបស់ កឹម សុខា នៅទីឃុំឃាំង, ដូច្នេះ បើនឹងចូលរួមជាមួយ សម រង្ស៊ី ដែល ហ៊ុន សែន ទុកជាសត្រូវ នឹងអាចមានការសងសឹកពីសំណាក់នរៈនេះ ទៅលើ កឹម សុខា។ ការណ៏ដែលក្រុម សម រង្ស៊ី ប្រើការពាក្យស្លោកថា « សម រង្ស៊ី និង កឹម សុខា ជាមនុស្សតែមួយ » ជាការចាំបាច់សំរាប់បង្ហាញ នូវការបន្តសកម្មភាព នៃគណបក្ស លើឆាក ជាតិ និង អន្តរជាតិ នៅពេលដែលប្រធានពេញច្បាប់ គ្មានលទ្ធភាព ធ្វើសកម្មភាពនយោបាយ។ ប៉ុន្តែ ចំពោះក្រុម កឹម សុខា, ប្រយោគនេះ វាមិនអាចទទួលយកបានដោយមានអំណរ ព្រោះវាអាចមាន គ្រោះថ្នាក់ដល់ កឹម សុខា ទៅវិញ។ បើសិនជាទំនាស់រវាងក្រុមទាំងពីរ វាឋិតនៅលើចំណុច ដែលបានរៀបរាប់ ជាសម្មតិកម្មខាងលើនេះ គឺវាជាគំនិតកញ្ជោត និង ជាបរាជ័យបន្តទៀតនៅចំពោះមុខអំណាចផ្តាច់ការជំនាញជាញជ័យ។ សួរថា តើបុគ្គល សម រង្ស៊ី ជាចម្លើយទៅនឹងការចាំបាច់ នៃស្ថានការណ៏ដែរឬទេ ?

**ឧប សៅ សង្ហា** **គំនិត** **២១ កក្កដា ២០១៨**